**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងព្រះសីហនុ
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ១២៥ ចុះថ្ងៃទី ២៨
ខែ មិថុនា ឆ្នាំ ២០០៤

<u>សាលក្រម</u>
លេខ ០៩ ចុះថ្ងៃទី ០៤
ខែ កុម្ភៈ ឆ្នាំ ២០០៥

សាលក្រមនេះបានចូលជាស្ថាពរហើយ ។
ក្រុងព្រះសីហនុ,ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥
ក្រឡាបញ្ជី
[redacted]

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក **គៀង សុន្ទរា**

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានជន ជាប់ចោទឈ្មោះ :

-**យ យ** ឈ្មោះក្រៅគ្មាន ភេទប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្បាលជ្រោយ កម្ពុជាក្រោម មានទីលំនៅសព្វថ្ងៃក្រុម ១១ ភូមិ ៣ សង្កាត់១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីចាំដីអោយគេ ឪពុកឈ្មោះ **ម ជ** (ស) ម្តាយឈ្មោះ **ម មយ** (រ) ប្រពន្ធឈ្មោះ **ម ស** មានកូន ០៥នាក់ ទោសពីមុន *គ្មាន* សព្វថ្ងៃរត់គេចខ្លួន ។

-ជនជាប់ចោទពីបទ<u>បង្ករបួសដោយចេតនា</u> ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ម ន** ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃក្រុមទី១១ ភូមិ ៣ សង្កាត់១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីរត់ម៉ូតូឌុប ជាជនរងគ្រោះ និង ដើមបណ្តឹង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២១ ដសព.០៥ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៨៧ តព.០៥ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៨៨ ត.៣/០៥ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :

-កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ ឈ្មោះ ៩ ៨ មានទំនាស់ជាមួយប្រពន្ធក៏បានដេរគ្នាទៅវិញទៅមក បន្ទាប់មកឈ្មោះ ៩ ៨ ក៏បានដើរចេញពីផ្ទះគាត់ដោយធ្វើដំណើរតាមផ្លូវដេរប្រពន្ធគាត់បណ្តើ ដើរបណ្តើរ រហូតដល់មុខផ្ទះឈ្មោះ យ យ ប្រពន្ធ យ យ ស្មានតែដេរខ្លួនគាត់ ក៏ប្រពន្ធ យ យ ដេរតទៅវិញ ពីព្រោះកន្លងមកក្រុមគ្រួសារទាំងពីរនេះធ្លាប់មានទំនាស់គ្នា ២លើករួចមកហើយ ឈ្មោះ ៩ ៨ បានប្រាប់ទៅប្រពន្ធ យ យ ថា ខ្លួនមិនដេរប្រពន្ធ យ យ ទេ គឺដេរប្រពន្ធខ្លួនគាត់តែប៉ុណ្ណោះ តែប្រពន្ធ យ យ មិនព្រមស្តាប់ ស្របពេលនោះឈ្មោះ យ យ បានយកកាំបិតកាប់ត្រូវ ៩ ៨ មួយកាំបិតបណ្តាលអោយមានរបួសចំក្បាល ក្រោយពេលប្រព្រឹត្តបទល្មើសរួចឈ្មោះ យ យ ក៏រត់គេចខ្លួនបាត់រហូតដល់សព្វថ្ងៃនេះជាមួយក្រុមគ្រួសារ ។

**នាពេលសវនាការ**

-ក្រឡាបញ្ជីអានដីកាចាប់ឈ្មោះ យ យ ភេទប្រុស អាយុ ៥៤ឆ្នាំ លេខ ២៥ ដច.០៥ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-ឈ្មោះ ៩ ៨ ជាជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា កន្លងមកក្រុមគ្រួសាររបស់ឈ្មោះ យ យ ធ្លាប់មានទំនាស់ជាមួយក្រុមគ្រួសារខ្លួនចំនួន ០២លើកមកហើយ នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ០៦ល្ងាច ខ្លួនក៏មានការឈ្លោះប្រកែកគ្នាជាមួយប្រពន្ធ ខ្លួនក៏ដើរទៅហូបកាហ្វេ ប្រពន្ធខ្លួនក៏ដើរតាមពីក្រោយខ្លួន នៅពេលដែលគាត់ដើរតាមក្រោយខ្លួននេះ ខ្លួននៅតែរអ៊ូរទាំដេរប្រពន្ធខ្លួនដដែល រហូតមកដល់ផ្ទះឈ្មោះ យ យ ស្រាប់តែប្រពន្ធ យ យ យល់ច្រឡំថា ខ្លួនដេរគាត់ក៏គាត់ដេរមកលើខ្លួន ទោះបីខ្លួនបានប្រាប់គាត់ថា ខ្លួនដេរប្រពន្ធខ្លួនទេ តែគាត់មិនស្តាប់នៅតែដេរមកលើខ្លួនដដែល ក៏ជជែកគ្នាទៅវិញទៅមក ស្រាប់តែឈ្មោះ យ យ មិនដឹងចេញមកពីកន្លែងណា យកកាំបិតផ្គាក់កាប់មកលើខ្លួន តែត្រូវមែកកាស្សាមុន ទើបដាច់មែក ហើយកាំបិតក៏ធ្លាក់ត្រូវចំក្បាលខ្លួនលើថ្ងាសបន្តិច បណ្តាលអោយមុត និង មានចេញឈាមពេញក្បាល និង មុខ ធ្វើអោយខ្លួនងងឹតមុខ និង សន្លប់បាត់ស្មារតី និង ត្រូវបានអ្នកជិតខាងជួយយកទៅពេទ្យចំការចេកសំរាកអស់រយៈពេល ១២ថ្ងៃ ដេរពាផ្ទេរបានអស់ទឹកប្រាក់ចំនួន ៣០០ដុល្លារ ។ ចំពោះបញ្ហានេះខ្លួនទាមទារសំណង ៣០០ដុល្លារ (បីរយដុល្លារ) និង សុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ចំពោះជនល្មើស ។

-ឈ្មោះ ឃ ស ជាសាក្សីបានឆ្លើយថា ខ្លួនបានឮសំលេងឈ្លោះគ្នារវាង ៩ ៨ និង ប្រពន្ធគាត់ ពេលនោះខ្លួនឃើញ ៩ ៨ ដើរបណ្តើរដេរប្រពន្ធគាត់បណ្តើររហូតដល់ផ្ទះ យ យ ប្រហែលជាមានការប៉ះពាល់ដល់ឈ្មោះ យ យ ក៏មានការទាក់មាត់ និង គ្នា ក៏ដេរគ្នាទៅវិញទៅមក ស្រាប់តែឃើញឈ្មោះ យ យ ក៏មានកាន់ដំបង ហើយមានបង្កប់ផ្លែកាំបិត ក៏កាប់ពីរកាំបិត ប៉ុន្តែត្រូវតែមួយកាំបិតចំលើចិញ្ចើមឈ្មោះ ៩ ៨ ក៏រត់ចេញមកក្រៅមានឈាមហូរយ៉ាងខ្លាំង ។ ខ្លួនក៏បានដឹក ៩ ៨ ទៅផ្ទះពេទ្យ តែមិនជួបពេទ្យ លុះព្រឹកឡើងយកឡានដឹកទៅពេទ្យចំការចេក ដោយឡែកឈ្មោះ យ យ ក្រោយពេលប្រព្រឹត្តបទល្មើសរួចបានរត់គេចខ្លួនទាំងប្រពន្ធ កូនមិនដឹងរស់នៅកន្លែងណាឡើយ ។ ឯផ្ទះគាត់សង់នៅលើដីរបស់គេតែប៉ុណ្ណោះ ព្រោះគាត់ជាអ្នកចាំដីអោយគេ ។ រឿងរ៉ាវអ្វីផ្សេងទៀតខ្លួនមិនបានដឹងឡើយ ។

-ឈ្មោះ ញ ៩ ជាសាក្សីបានឆ្លើយថា នៅក្នុងអំឡុងឆ្នាំ ២០០៤ ថ្ងៃ ខែ មិនចាំវេលាម៉ោង ០៦ជាងខ្លួនកំពុងតែហូបបាយ ខ្លួនក៏បានឮសំឡេង ៩ ៨ គាត់ឈ្លោះគ្នាជាមួយប្រពន្ធគាត់ ខ្លួនក៏ឃើញឈ្មោះ ៩ ៨ គាត់ដើរចេញពីផ្ទះគាត់ តែឮគាត់នៅតែដេរប្រពន្ធគាត់ដដែល រហូតមកដល់ផ្ទះឈ្មោះ យ យ ស្មានថា ឈ្មោះ ៩ ៨ ដេរគាត់

ក៏មានការឈ្លោះគ្នា និង ជេរគ្នា ខ្លួនក៏ឃើញឈ្មោះ **ឃ ឃ** ទាញកាំបិតពីក្នុងផ្ទះគាត់មកកាប់ **៩ ឆ** ក៏ត្រូវមែកកាស្វា ហើយក៏ដាច់មែកកាស្វា ហើយកាំបិតក៏ធ្លាក់ចុះមកក៏ត្រូវចំក្បាល **៩ ឆ** បណ្តាលអោយមានឈាមហូរយ៉ាងខ្លាំង និង ឃើញ **៩ ឆ** ដួលទៅនឹងដី បន្ទាប់មកក៏បានអ្នកជិតខាងដឹកគាត់ទៅមន្ទីរពេទ្យចំការចេក រឿងរ៉ាវអ្វីផ្សេងទៀតខ្លួនមិនបានដឹងទេ ។

-ឈ្មោះ **ច សច** ជាសាក្សីបានឆ្លើយថា នៅមុនពេលកើតហេតុ ខ្លួនកំពុងតែហូបបាយ ស្រាប់តែឮសំឡេងឈ្លោះគ្នា ក៏ចេញទៅមើល ក៏ឃើញឈ្មោះ **ឃ ឃ** និង ឈ្មោះ **៩ ឆ** ឈ្លោះគ្នា ក៏ឃើញឈ្មោះ **ឃ ឃ** បានកាប់ទៅលើ **៩ ឆ** មួយកាំបិតត្រូវចំក្បាលបណ្តាលអោយមានឈាមហូរយ៉ាងខ្លាំង ខ្លួនក៏ស្រែកថា ម៉េចមិនជួយ **៩ ឆ** គឺស្រែកអោយអ្នកជិតខាងជួយ ព្រោះឃើញមានឈាមហូរ និង ស្រែកអោយគេបិតថ្នាំផង ឯរឿងរ៉ាវផ្សេងទៀតខ្លួនមិនបានដឹងទេ ។

-ឈ្មោះ **ស ៖** ជាសាក្សីបានឆ្លើយថា មុនពេលកើតហេតុខ្លួននៅមុខផ្ទះឈរលេង ស្រាប់តែឮសំឡេង **៩ ឆ** ឈ្លោះគ្នាជាមួយប្រពន្ធគាត់ ក៏ឃើញ **៩ ឆ** ដើរចេញពីផ្ទះគាត់តែនៅតែជេរប្រពន្ធគាត់ដដែល រហូតដល់ផ្ទះ **ឃ ឃ** ឮគេថា កាប់គ្នា ខ្លួនក៏រត់ទៅមើល ក៏ឃើញ **៩ ឆ** មានឈាមហូរយ៉ាងច្រើននៅលើចិញ្ចើម ក៏ត្រូវបានអ្នកជិតខាងយកគាត់ទៅមន្ទីរពេទ្យ ឯរឿងរ៉ាវអ្វីផ្សេងទៀត ខ្លួនមិនបានដឹងឡើយ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ឃ ឃ** ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង សុំអោយតុលាការសំរេចទៅតាមច្បាប់ដោយក្តីអនុគ្រោះ ។

-ក្រោយពីបានឃើញដីកាចាប់ខ្លួន

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-កន្ទងមកគ្រួសារ **ឃ ឃ** និង ក្រុមគ្រួសាររបស់ឈ្មោះ **៩ ឆ** តែងតែមានទំនាស់ជាញឹកញាប់ ជាពិសេស **ឃ ឃ** ជាមួយឈ្មោះ **៩ ឆ** ។

-តាមចម្លើយរបស់ឈ្មោះ **៩ ឆ** ថា នៅមុនពេលកើតហេតុ ខ្លួនមានការឈ្លោះគ្នាជាមួយប្រពន្ធរបស់គាត់ ហើយគាត់នៅតែរអ៊ូរទាំប្រពន្ធគាត់ដដែល ព្រមទាំងជេរប្រពន្ធគាត់ទៀត រហូតដល់ផ្ទះ **ឃ ឃ** ស្របពេលនោះប្រពន្ធ **ឃ ឃ** ស្មានថា តែ **៩ ឆ** ជេរមកលើខ្លួន ក៏ជេរតបទៅវិញ ក៏មានប្រកែកគ្នា ឈ្មោះ **ឃ ឃ** ក៏បានកាប់ **៩ ឆ** តែត្រូវមែកឈើ ហើយដាច់មែកឈើកាំបិតធ្លាក់ត្រូវចំក្បាលថ្ងាសខាងលើ មានរបួសក៏បានសំរាកព្យាបាលនៅមន្ទីរពេទ្យចំការចេក ។

-ឈ្មោះ **ឃ ឃ** ក្រោយពេលប្រព្រឹត្តបទល្មើសរួច ក៏នាំប្រពន្ធ កូន រត់គេចខ្លួនរហូតមកដល់សព្វថ្ងៃ ប៉ុន្តែឈ្មោះនេះមានប្រវត្តិរូបច្បាស់លាស់ ហើយត្រូវបានចៅក្រមស៊ើបអង្កេតចេញដីកាចាប់ខ្លួនរួចហើយដែរ ។

-តាមចម្លើយសាក្សីបានឆ្លើយប្រហាក់ប្រហែលគ្នាថា ឈ្មោះ ឃ ឃ ពិតជាបានយកកាំបិតកាប់ទៅលើ ឈ្មោះ ជ ឆ ពិតប្រាកដមែន បណ្តាលអោយឈ្មោះ ជ ឆ មានរបួស និង មានឈាមរហូតដល់សន្លប់ ចម្លើយនេះ មានមូលដ្ឋានគួរអោយតុលាការជឿបាន ។

-បណ្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាលរបួស និង ជំងឺចិត្តរបស់ជនរងគ្រោះ និង ដើមបណ្តឹងមានលក្ខណៈ សមស្របតាមច្បាប់ ហេតុនេះតុលាការពិចារណាដល់បញ្ហានេះ ។

-ជនជាប់ចោទបន្សល់ទុកនៅសំបកផ្ទះមួយនៅលើដីរបស់អ្នកដទៃតែប៉ុណ្ណោះ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឃ ឃ ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោស តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះតុលាការ ក្រុងព្រះសីហនុ

## សំ រេ ច :

ផ្តន្ទាទោស :

១-ឈ្មោះ ឃ ឃ ភេទប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃ ចាប់ខ្លួនបាន និង យកមកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ក្រោយសាលក្រមនេះចូលជាស្ថាពរ ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-អោយឈ្មោះ ឃ ឃ សងសំណងថ្លៃថ្នាំព្យាបាល និង ជំងឺចិត្តជាទឹកប្រាក់ចំនួន ១.២០០.០០០៛០០ (មួយលាន ពីររយពាន់រៀល) ទៅជនរងគ្រោះឈ្មោះ ជ ឆ គិតពីសាលក្រមនេះចូលជាស្ថាពរ ។

ក្នុងករណីទណ្ឌិតគ្មានប្រាក់ធនធានទេ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុក បង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនរងគ្រោះ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជំរះ

[redacted]